# ព័ន្ធកិច្ចលោកដេរេក ព្រីនស៍ DEREK PRINCE

# សេចក្តីបង្រៀនតាមសំបុត្រ

## តើលោកអ្នកដឹងទេ ថាលោកអ្នកមានតម្លៃប៉ុណ្ណា?

អស់រយៈពេលជាងហាសិបឆ្នាំមកហើយ ខ្ញុំបានព្យាយាមជួយមនុស្សជាច្រើនចំពោះបញ្ហាផ្សេងៗជាច្រើនរាប់មិនអស់នៅក្នុងជីវិតរបស់ពួកគេ។ ទីបំផុត ខ្ញុំក៏បានធ្វើការសន្និដ្ឋាន ដ៏គួរភ្ញាក់ផ្អើលមួយៈ បញ្ហាជាមូលដ្ឋានរបស់មនុស្សគឺថា យើងមិនដឹងថា ខ្លួនយើងមានតម្លៃប៉ុណ្ណា។

ដូច្នេះយើងបានធ្វើកំហុសជាច្រើន ដែលមានការអន្តរាយបំផុត។ យើងប្រៀបបីដូចជាមនុស្សម្នាក់ មានសំណាងយ៉ាងធំ ដែលជាអ្នកស្នងមរតកស្របច្បាប់ ប៉ុន្តែផ្ទុយទៅវិញ យើងលក់កេរ្តិ៍មរតករបស់យើងទាំងអស់ ក្នុងតម្លៃមួយទាបដែលមិនអាចប្រៀបធៀបបានៈ នៅពេលយប់មួយបានភ្លាត់រួមភេទខុសពីសីលធម៌ ចូលរួមប្រើគ្រឿងញៀន ស្រវឹងស្រានៅពេលជប់លៀងក្លែងបន្លំបញ្ជីឯកសារហិរញ្ញវត្ថុ ។

ឬប្រហែលជាយើងអោយតម្លៃខ្លួនឯងខ្ពស់ជាងហ្នឹងបន្តិច ដោយស្វែងរកតំណែងដែលមានកេរ្តិ៍ឈ្មោះក្នុងឆាកនយោបាយ ឬក្នុងពិភពកម្សាន្ត ឬសូម្បីតែតំណែងខ្ពស់ខាងសាសនានៅតាមការិយាល័យណាមួយក៏បាន។ ប៉ុន្តែសម្រាប់កេរ្តិ៍ឈ្មោះទាំងអស់នេះ វាមិនអាចប្រៀបធៀបទៅនឹងតម្លៃនៃកេរ្តិ៍មរតករបស់យើង ដែលយើងយកទៅដោះដូរជាមួយនោះបានទេ។

ប្រសិនបើយើងចង់មើលឃើញពីគុណតម្លៃពិតរបស់យើងជាមនុស្ស យើងត្រូវពិចារណាមើលពីរបៀបតែមួយគត់ និងដ៏អស្ចារ្យ ដែលលោកអាដាម ជាបុព្វបុរសនៃមនុស្សជាតិរបស់យើងត្រូវបានបង្កើតឡើង។

## ភាពអស្ចារ្យក្នុងការបង្កើតលោកអដាំ

នៅក្នុងគម្ពីរ**យ៉ូហាន១:១-២** យើងរកឃើញថា ភ្នាក់ងារដែលសកម្មក្នុងការបង្កើត មិនមែនជាព្រះជាម្ចាស់ ដ៏ជាព្រះបិតានោះទេ ប៉ុន្តែគឺជាព្រះបន្ទូល ដែលបានគង់នៅជាមួយព្រះជាម្ចាស់តាំងពីអស់កល្បជានិច្ចវិញ **គឺជាបុគ្គលដែលក្រោយមក ត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស ថាជាព្រះយេស៊ូមកពីភូមិណាសារ៉ែត**:*"អ្វីៗសព្វសារពើសុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្តាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពីព្រះអង្គបង្កើតនោះឡើយ ។*

ការបង្កើតទាំងអស់ ត្រូវបានលេចចេញមក ដោយសារព្រះបន្ទូលចេញមកពីព្រះជាម្ចាស់: *«ដោយសារជំនឿ យើងយល់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្កើតពិភពលោកមក»* ។[១] *«ដ្បិតអ្វីៗទាំងអស់កើតមាន ដោយសារព្រះបន្ទូលរបស់ព្រះអង្គ ព្រះអង្គបង្គាប់យ៉ាងណា ក៏កើតមានយ៉ាងនោះមែន»* ។[២] ប៉ុន្តែចំពោះការបង្កើតលោកអដាំវិញ ដូចមានចែងនៅក្នុងគម្ពីរ**លោកុប្បត្តិ២:៧** ពិតជាមានតែមួយគត់ ដែលខុសប្លែកពីការបង្កើតផ្សេងទៀត: *«ព្រះជាអម្ចាស់បានយកធូលីដី មកសូនធ្វើជាមនុស្ស រួចព្រះអង្គផ្លុំដង្ហើមជីវិតតាមរន្ធច្រមុះគេ មនុស្សក៏មានជីវិតរស់ឡើង (មានន័យថា ជាព្រលឹងដែលមានជីវិត)»* ។

ចូរស្រមៃមើលពីទិដ្ឋភាពនេះមើល៍! ព្រះអម្ចាស់បានលុតជង្គង់ចុះ ហើយយកធូលីដីនៅក្នុងព្រះហស្តរបស់ទ្រង់ មកលាយជាមួយនឹងទឹក និងសូនវាឲ្យក្លាយទៅជារាងកាយរបស់បុរសម្នាក់។ ដូច្នេះ នេះគឺជារូបចម្លាក់ល្អឥតខ្ចោះបំផុត ដែលមិនធ្លាប់មានអ្នកច្នៃពីមុនមក ហើយល្អឥតខ្ចោះជាងស្នាដៃឆ្លាក់រូបរបស់លោក ម៉ៃឃេលេនហ្គីឡូ (Michelangelo) ទៅទៀត។ ប៉ុន្តែវាមិនមានជីវិតនោះទេ! បន្ទាប់មកមានការដ៏អស្ចារ្យមួយបានកើតឡើង គឺព្រះដ៏ជាអាទិករបានផ្អៀងទៅមុខដាក់បបូរមាត់ខាងឯវិញ្ញាណរបស់ទ្រង់ទល់ នឹងបបូរមាត់របស់ដីឥដ្ឋ ដាក់ច្រមុះខាងឯវិញ្ញាណរបស់ទ្រង់ទល់នឹងច្រមុះរបស់ដីឥដ្ឋ រួចព្រះអង្គផ្លុំដង្ហើមជីវិតតាមរន្ធច្រមុះដីឥដ្ឋនោះ។ ដង្ហើមជីវិតរបស់ទ្រង់បានទម្លាយចូលទៅក្នុងរាងកាយរបស់ដីឥដ្ឋ និងផ្លាស់ប្តូរវាទៅជាមនុស្សដែលមានជីវិតដោយគ្រប់ទាំងសរីរាង្គរបស់រូបកាយទាំងអស់ មានមុខងារដំណើរយ៉ាងល្អឥតខ្ចោះ រួមជាមួយនឹងការឆ្លើយតបខាងឯអារម្មណ៍ បញ្ញា និង វិញ្ញាណដ៏អស្ចារ្យទាំងអស់ ដែលមនុស្សមានសមត្ថភាព។ ហើយគ្មានរបស់មានជីវិតណាផ្សេងទៀត ដែលត្រូវបានបង្កើតឡើងក្នុងរបៀបដូចនេះទេ។

ពាក្យដែលត្រូវបានគេប្រើ ដើម្បីពិពណ៌នាអំពីការដ៏អស្ចារ្យនេះ គឺមានភាពរស់រវើកយ៉ាងពិសេស។ ហេប្រឺគឺជាភាសាមួយ នៃភាសាទាំងឡាយ ដែលមានសំឡេងនៃពាក្យមួយចំនួន ត្រូវបានទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាព ដែលត្រូវបានពណ៌នានោះ។ សំឡេងនៃពាក្យជាភាសាហេប្រឺដែលត្រូវបានគេបកប្រែ ពាក្យថាផ្លុំដង្ហើម អាចប្រែថាជា យីប៉ាក (yipakh)។ វាបានកើតឡើងពី: «ការផ្ទុះ» នៃផ្ទៃខាងក្នុងដ៏តូច ដែលបានរុញច្រានតាមពីក្រោយ ជាបន្តបន្ទាប់ឥតដាច់នៃខ្យល់ដែលបានចេញពីបំពង់កមក។ ដូច្នេះវាតំណាងឱ្យសកម្មភាពយ៉ាងរស់រវើក ដូចដែលបានពិពណ៌នាមក។ ខណៈពេលដែលព្រះអម្ចាស់បានឱនចុះពីលើបបូរមាត់ និងរន្ធច្រមុះរបស់ដីឥដ្ឋនោះ ព្រះអង្គមិនបានបញ្ចេញដង្ហើម ដោយខ្សោយល្វើយនោះទេ ប៉ុន្តែទ្រង់បានផ្លុំដង្ហើមចូលទៅក្នុងរូបកាយដីឥដ្ឋនោះយ៉ាងខ្លាំងវិញ ក្នុងរបៀបដូច្នេះហើយ ដែលមនុស្សទទួលបាន នូវជីវិតដ៏អស្ចារ្យ ដែលព្រះជាម្ចាស់ចែកប្រទានឲ្យ!

ភ្លាមនោះបុរសបានក្លាយជាភាពត្រីឯក ដែលមានសមាសភាពបានមកពី វិញ្ញាណ ព្រលឹង និងរូបកាយលាយបញ្ចូលគ្នា។ វិញ្ញាណបានចេញមកពីដង្ហើមរបស់ព្រះជាម្ចាស់ ដែលដកចេញដកចូល រូបកាយរបស់គាត់គឺបានមកពីដីឥដ្ឋ ហើយត្រូវបានបំលែងទៅជាជីវិតរស់រវើក ដោយ

សាច់ឈាមដែលមានជីពចរដំណើរការ ចំណែកឯព្រលឹងរបស់គាត់វិញ ត្រូវបានផលិតឡើងដោយការរួមបញ្ចូលគ្នារវាងវិញ្ញាណ និងរូបកាយ បានក្លាយមកមានភាពតែមួយគត់ មានបុគ្គលិកលក្ខណៈជាឯកត្តជន មានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តបាន-**ខ្ញុំនឹង** ឬ**ខ្ញុំនឹងមិន**។

រួមជាមួយនឹងមិត្តសម្លាញ់ដែលព្រះជាម្ចាស់ប្រទានឱ្យ លោកអដាំក៏ត្រូវបានតែងតាំងឲ្យគ្រប់គ្រងលើផែនដី ដោយធ្វើជាតំណាងរបស់ព្រះអង្គផងដែរ។ ភាពបីរួមមកតែមួយនៃធម្មជាតិខាងក្នុងរបស់គាត់តំណាងឱ្យភាពដូចគ្នា នៃភាពជាព្រះត្រីឯក របស់ព្រះជាម្ចាស់។ រូបរាងខាងក្រៅរបស់គាត់ គឺជាកញ្ចក់ឆ្លុះបញ្ចាំងពី***រូបភាព***របស់ព្រះអម្ចាស់ ដែលបានបង្កើតគាត់។[៣]តាមរយៈរូបកាយធម្មជាតិខាងក្នុង និងរូបកាយខាងក្រៅរបស់គាត់ ទាំងពីរហ្នឹងធ្វើឲ្យគាត់ក្លាយជាតំណាងរបស់ព្រះជាម្ចាស់ ដែលមានតែមួយគត់ ចំពោះសត្វលោកទាំងអស់នៅលើផែនដីនេះ។

លើសពីនេះទៀតអដាំ និងអេវ៉ាបានរីករាយ ដោយមានការប្រកបផ្ទាល់ខ្លួនជាមួយនឹងព្រះអម្ចាស់ជាទៀងទាត់។ នៅពេលចុងបញ្ចប់នៃថ្ងៃនីមួយៗ ទ្រង់បានយាងមកដើម្បីចំណាយពេលវេលាជាមួយពួកគេ។[៤] មាននរណាដឹងទេថា តើអ្វីទៅជាការបើកសម្តែងរបស់អង្គទ្រង់ផ្ទាល់ ដែលទ្រង់បានចែករំលែកឲ្យពួកគេនោះ? ទោះបីជាយ៉ាងណាក៏ដោយ យើងពិតជាដឹងថាព្រះជាម្ចាស់បានផ្តល់ឯកសិទ្ធិឲ្យអដាំ ជ្រើសរើសឈ្មោះសម្រាប់ដាក់អោយសត្វលោក ដែលមានជីវិតផ្សេងទៀតទាំងអស់។[៥]

សោកនាដកម្មដ៏ធំបំផុត នៃប្រវត្តិសាស្ត្ររបស់មនុស្សលោកដែលតមក គឺមនុស្សត្រូវបានសាតាំងបោកបញ្ឆោត។ អដាំនិងអេវ៉ាបានជួញដូរកេរ្តិ៍មរតកដែលព្រះប្រទានឱ្យពួកគេ ជាមួយនឹងផ្លែឈើដឹងខុសត្រូវ! ការមិនស្តាប់បង្គាប់នេះ បានប៉ះពាល់ដល់គ្រប់ផ្នែក នៃធម្មជាតិបីរួមមកតែមួយរបស់អដាំ។ វិញ្ញាណរបស់គាត់-ត្រូវបានកាត់ផ្តាច់ចេញពីព្រះជាម្ចាស់-បានស្លាប់។ក្នុងព្រលឹងរបស់គាត់ គាត់បានក្លាយជាអ្នកបះបោរម្នាក់ ដែលចាប់តាំងពីពេលនេះទៅ គាត់ធ្វើសង្គ្រាមជាមួយនឹងព្រះអាទិករដែលបង្កើតរូបគាត់វិញ។ រាងកាយរបស់គាត់បានទទួលរងនូវជំងឺ ភាពវ័យចំណាស់ ហើយចុងក្រោយត្រូវស្លាប់។

ព្រះជាម្ចាស់បានព្រមានអដាំអំពីដើមឈើដឹងខុសត្រូវនេះថា៖ *«ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន»។*[៦] វាគឺជាវិញ្ញាណរបស់អដាំដែលបានស្លាប់ភ្លាមនោះ! ប៉ុន្តែរូបរាងកាយរបស់គាត់ នៅរស់បានជាងប្រាំបួនរយឆ្នាំទៀត ទើបបានស្លាប់។

---

## ភាពអស្ចារ្យនៃការប្រោសលោះរបស់ព្រះគ្រិស្ត

---

ការមិនស្តាប់បង្គាប់របស់អដាំ គឺជាការនាំមកនូវផលវិបាក ដែលគួរឱ្យភ័យខ្លាចជាច្រើនមកជាមួយ ប៉ុន្តែទោះបីជាអញ្ចឹងក៏ដោយ វាបាននាំយកមកនូវទិដ្ឋភាពច្បាស់មួយអំពីលក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ ដែលពីមុនមក មិនដែលត្រូវបានបើកសម្តែងចេញ អោយបានពេញលេញនោះគឺ: ជម្រៅទឹកព្រះទ័យនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលយើងពុំអាចវាស់បាន។

**ព្រះជាម្ចាស់មិនដែលបោះបង់ចោលលោកអដាំ និងពូជពង្សរបស់គាត់នោះទេ។** ព្រះអង្គមានព្រះហឫទ័យចង់នាំយើងត្រឡប់មករកទ្រង់វិញ។

ព្រះហឫទ័យនេះ ត្រូវបានសម្ដែងយ៉ាងច្បាស់ នៅគម្ពីរយ៉ាកុប ៤: ៥ "ព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់វិញ្ញាណ ដែលព្រះអង្គប្រទានអោយមកគង់ក្នុងបងប្អូន រហូតដល់ប្រច័ណ្ឌ" ជាវិញ្ញាណ ដែលព្រះអង្គបានផ្លុំបញ្ចូលទៅក្នុងខ្លួនអដាំ នៅពេលទ្រង់បង្កើតរូបគាត់។ អ្វីដែលមិនគួរឱ្យជឿនោះគឺថា ព្រះជាម្ចាស់នៅតែចង់បន្តធ្វើការប្រកបផ្ទាល់ខ្លួន ដែលទ្រង់ធ្លាប់មានភាពរីករាយជាមួយនឹងអដាំពីមុនមក ប៉ុន្តែវាត្រូវបានកាត់ផ្ដាច់ដោយសារការបះបោររបស់អដាំ គឺជាការបះបោរមួយដែលស្ថិតនៅជាប់នឹងពូជពង្សទាំងអស់របស់អដាំជានិច្ច។

លើសពីនេះទៅទៀត នៅក្នុងការចំណាយដែលគ្មានទីបញ្ចប់ ព្រះជាម្ចាស់ក៏បានប្រទានមធ្យោបាយមួយមកដើម្បីស្ដារទំនាក់ទំនងរវាងយើង និងទ្រង់ឡើងវិញ ដោយព្រះអង្គបានចាត់បញ្ជូនព្រះយេស៊ូ"បុត្រមនុស្សបានមក ដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់"។[៧] ដោយការថ្វាយយញ្ញបូជាជំនួស របស់ទ្រង់នៅលើឈើឆ្កាង ព្រះយេស៊ូបានធ្វើឱ្យវាអាចទៅរួចសម្រាប់យើងម្នាក់ៗ ដោយយើងត្រូវបានលើកលែងទោស និងសម្អាតពីអំពើបាបហើយក្លាយទៅជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់ផ្ទាល់។

ក្នុង**ម៉ាថាយ១៣:៤៥-៤៦** ព្រះយេស៊ូ បានមានព្រះបន្ទូលជាប្រស្នា-ដែលសម្រាប់ខ្ញុំផ្ទាល់-ពណ៌នាអំពីការប្រោសលោះដ៏អស្ចារ្យរបស់យើង ដោយមានខ្លឹមសារយ៉ាងពិរោះបំផុតថា៖ *"ម្យ៉ាងទៀត ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាអ្នកជំនួញម្នាក់ ដែលស្វែងរកទិញពេជ្រល្អៗ។ កាលបានឃើញពេជ្រមួយគ្រាប់ដ៏មានតម្លៃលើសលប់ហើយ គាត់ក៏ទៅលក់អ្វីៗទាំងប៉ុន្មានដែលគាត់មានយកប្រាក់មកទិញពេជ្រនោះ"*។

សម្រាប់ខ្ញុំ នេះគឺជាការពិពណ៌នាពីការប្រោសលោះនៃព្រលឹងរបស់មនុស្សម្នាក់។ ព្រះយេស៊ូ គឺជាអ្នកជំនួញម្នាក់ មិនមែនជាអ្នកទេសចរណ៍ ឬក៏ជាអ្នកដើរលេងកំសាន្តទេ-ប៉ុន្តែគឺជាបុរសម្នាក់ ដែលបានធ្វើការងារទាក់ទងនឹងពេជ្រ ពេញមួយជីវិតរបស់គាត់ ហើយដឹងពីតម្លៃពិតប្រាកដរបស់ពេជ្រនីមួយៗថែមទៀតផង។ ពេជ្រដែលទ្រង់បានទិញនេះ គឺជាព្រលឹងរបស់មនុស្សម្នាក់ លោកអ្នក ឬខ្ញុំ។ ព្រលឹងនេះមានតម្លៃស្មើនឹងអ្វីៗទាំងអស់ដែលទ្រង់មាន-អ្វីៗគ្រប់យ៉ាងដែលទ្រង់ធ្វើជាម្ចាស់កម្មសិទ្ធិ។

បើធ្វើបច្ចុប្បន្នភាពឲ្យទៅជា វប្បធម៌សហសម័យរបស់យើងវិញ ខ្ញុំពិពណ៌នាដោយផ្ទាល់ខ្លួនពីទិដ្ឋភាពនេះថា នៅពេលដែលអ្នកជំនួញ បានទម្លាយដំណឹងនេះទៅកាន់ភរិយារបស់គាត់។

"អូនសម្លាញ់! បងបានលក់ឡានរបស់យើងហើយ"។

"បងបានលក់ឡានរបស់យើងហើយ! មិនអីទេ យ៉ាងហោចណាស់យើងនៅសល់ដំបូលសម្រាប់ជ្រកដែរ"។

"អត់ទេអូន បងក៏បានលក់ទាំងផ្ទះរបស់យើងដែរ"

"តើមានអ្វីទៅដែលបណ្ដាលឲ្យបងធ្វើការទាំងអស់ហ្នឹង"?

"បងបានរកឃើញពេជ្រដ៏ស្រស់ស្អាតបំផុត ដែលបងធ្លាប់បានឃើញពីមុនមក។ បងបាន

ខិតខំស្វែងរកពេជ្រមួយគ្រាប់ដូចនេះ អស់ពេញមួយជីវិតរបស់បង។ ពេជ្រនេះវាមានតម្លៃស្មើនឹងអ្វីៗទាំងអស់ដែលបងមាន។ សូមអូនរង់ចាំមើល រហូតដល់ពេលឃើញវា ទើបដឹង!

ដូច្នេះ តើនេះមានអត្ថន័យអ្វីចំពោះលោកអ្នក និងខ្ញុំ? យើងម្នាក់ៗប្រហែលជា មើលឃើញពីខ្លួនយើងថា ដូចជាគ្រាប់ពេជ្រដែលគ្មានតម្លៃ។

សូមចងចាំថា វាមានតម្លៃស្មើនឹងអ្វីៗគ្រប់យ៉ាងដែលព្រះយេស៊ូមាន ដើម្បីទិញលោកអ្នកយកត្រឡប់មកឯទ្រង់វិញ។ ទោះបីជាព្រះអង្គ ជាព្រះអម្ចាស់នៃសកលលោកទាំងមូលក៏ដោយ ព្រះអង្គបានដាក់វាទុកទាំងអស់ចេញមួយឡែក ហើយបានសុគតនៅក្នុងភាពក្រីក្រយ៉ាងជាក់។ ទ្រង់មិនមានអ្វីជាកម្មសិទ្ធិទៀតទេ។ សំពត់ និងផ្នូរដែលគេកប់សពទ្រង់ ទាំងពីរហ្នឹង សុទ្ធតែបានមកពីខ្ចីគេទាំងអស់។ *«គឺព្រះអង្គមានសម្បត្តិដ៏ច្រើន ទ្រង់បានដាក់ខ្លួនមកជាអ្នកក្រ ព្រោះតែបងប្អូន ដើម្បីអោយបងប្អូនបានទៅជាអ្នកមាន ដោយភាពក្រីក្ររបស់ព្រះអង្គ»* ។[៨]

ប្រហែលជាលោកអ្នកមិនដែលមើលឃើញខ្លួនឯងថាជាមនុស្សមានតម្លៃសំខាន់នោះទេ។ លោកអ្នកមានរូបរាងអាក្រក់។ លោកអ្នកប្រហែលជាគិតពី ជីវិតដែលមានការឈឺចាប់ និងមានការខកចិត្តពីរឿងអតីតកាលៈ ត្រូវគេបដិសេធ និងកុមារភាពដែលមិនរីករាយ អាពាហ៍ពិពាហ៍មួយដែលបានបញ្ចប់ដោយការលែងលះគ្នា ឬអាជីពមួយ ដែលមិនដែលបានទទួលធនធានឲ្យបានគ្រប់គ្រាន់សម្រាប់ធ្វើការ ឬបានខ្ជះខ្ជាយពេលវេលាជាច្រើនឆ្នាំទៅលើការប្រើថ្នាំញៀន និងសេពគ្រឿងស្រវឹង។ អតីតកាល និងអនាគតរបស់លោកអ្នក ទាំងពីរហ្នឹង សុទ្ធតែបង្ហាញសារដូចគ្នាថាៈ បរាជ័យ!

បរាជ័យមិនមែនសម្រាប់ព្រះយេស៊ូទេ! ព្រះអង្គស្រឡាញ់លោកអ្នកខ្លាំងណាស់ ហេតុនេះហើយបានជាទ្រង់ លះបង់អ្វីៗទាំងអស់គ្រប់យ៉ាងដើម្បីប្រោសលោះលោកអ្នក។ សូមនិយាយតាមខ្ញុំ នូវពាក្យសំដីដ៏ពិរោះមានន័យរបស់សាវកប៉ូល ហើយធ្វើឱ្យពាក្យទាំងអស់ហ្នឹងក្លាយទៅជាពាក្យសំដីផ្ទាល់ខ្លួនរបស់លោកអ្នកៈ *«ព្រះអង្គបានស្រឡាញ់ខ្ញុំ និង បានបូជាព្រះជន្មសំរាប់ខ្ញុំ»*។ សូមនិយាយម្តងទៀត *«ព្រះអង្គបានស្រឡាញ់ខ្ញុំ និង បានបូជាព្រះជន្មសំរាប់ខ្ញុំ»* និងម្តងទៀតថា *«ព្រះអង្គបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសំរាប់ខ្ញុំ»* ។[៩]

ឥឡូវនេះ សូមលោកអ្នកមើលមកខ្លួនឯង ដូចជាគ្រាប់ពេជ្រមួយគ្រាប់ ដែលស្ថិតនៅក្នុងព្រះហស្ថមានស្នាមចោះដែកគោលរបស់ព្រះយេស៊ូ។ ចូរស្តាប់ព្រះអង្គ ទ្រង់មានព្រះបន្ទូលមកកាន់លោកអ្នកថា «អ្នកមានភាពស្រស់ស្អាតខ្លាំងណាស់! ខ្ញុំបានចំណាយអ្វីៗទាំងអស់ ដែលខ្ញុំមាន ដើម្បីទិញអ្នកយកមក ប៉ុន្តែខ្ញុំមិនសោកស្តាយទេ។ ឥឡូវនេះអ្នកជារបស់ខ្ញុំជារៀងរហូត!»

លោកអ្នកមិនអាចធ្វើអ្វីបាន ដើម្បីរកឲ្យបានការនេះទេ។ លោកអ្នកមិនអាចផ្លាស់ប្តូរ ឬធ្វើឱ្យខ្លួនលោកអ្នកបានល្អ ដោយខ្លួនឯងនោះទេ។ អ្វីទាំងអស់ ដែលអ្នកអាចធ្វើបាន គឺទទួលយកនូវអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់អ្នក និងសូមអរព្រះគុណដល់ទ្រង់!

**អ្នកជារបស់ទ្រង់ជារៀងរហូត!**

ដកស្រង់មកពីកេរ្តិ៍ដំណែលរបស់លោកដេរេក ព្រីនស៍ DEREK PRINCE តាមកម្មវិធីវិទ្យុតាគ«តើលោកអ្នកដឹងទេ ថាលោកអ្នកមានតម្លៃប៉ុណ្ណា?»

[១] ហេប្រឺ១១:៣
[២] ទំនុកតម្កើង៣៣:៩
[៣] លោកុប្បត្តិ១:២៦-២៧
[៤] លោកុប្បត្តិ៣:៨
[៥] លោកុប្បត្តិ២:១៩
[៦] លោកុប្បត្តិ២:១៧
[៧] លូកា១៩:១០
[៨] ២កូរិនថូស៨:៩
[៩] កាឡាទី២:២០